BMI0130

# សម្ភាសជាមួយឈ្មោះ ឡាច គា ភេទស្រី អាយុ៥៨ ឆ្នាំ

## មុខងារខ្មែរក្រហមៈ “នៅកងចល័ត”

## សព្វថ្ងៃរស់នៅភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី

០០:៥៣:០៩

២៨ទំព័រ

ដានី : អញ្ចឹងជំបូងខ្ញុំសុំស្គាល់ឈ្មោះមីងៗអាយុប៉ុន្មានហើយសព្វថ្ងៃ?

គា : ខ្ញុំអាយុ៥៨ហើយ ។

ដានី : បាទ!មីងសព្វថ្ងៃរស់នៅភូមិឃុំអីដែរ?

គា : នៅភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

ដានី : ភូមិប៉ោយក្តឿង ឃុំព្រះនេត្រព្រះ?

គា : ចាំ! ស្រុកព្រះនេត្រព្រះ ។

ដានី : បាទ!ប្តីមីងគាត់ឈ្មោះអីទៅ?

គា : ឈ្មោះ ធីម ឆន ។

ដានី : ធីម ឆន?

គា : ចាំ!ឈ្មោះធីម ឆន ។

ដានី : គាត់អាយុប៉ុន្មានដែរ?

គា : អាយុ៦០ឆ្នាំ ។

ដានី : មីងមានកូនចៅទាំងអស់ប៉ុន្មាននាក់?

គា : ១នាក់ ។

ដានី : ស្រីឬប្រុស១ម្នាក់ ។

គា : ស្រី ។

ដានី : សព្វថ្ងៃមីងប្រកបមុខរបរធ្វើអីដែរ?

គា : ធ្វើស្រែ ។

ដានី : មីងឪពុកមីងគាត់ឈ្មោះអីទៅ?

គា ៖ ឈ្មោះ ឡាច វឿន ។

ដានី ៖ ឡាច វឿនសព្វថ្ងៃគាត់នៅរស់ឬក៏?

គា ៖ ស្លាប់អស់ហើយ ។

ដានី ៖ បាទ!ស្លាប់តាំងពីអន្កាល់?

គា ៖ សម័យយើងនេះ ។

ដានី ៖ បាទ!ចុះម្ដាយ?

គា ៖ ម្ដាយឈ្មោះ ខ្វឹន ឡោម ។

ដានី ៖ គាត់នៅរស់ឬក៏ស្លាប់ដែរ?

គា ៖ ស្លាប់ទាំងអស់គ្នា ។

ដានី ៖ ចុះមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

គា ៖ បងប្អូនបង្កើត៦នាក់ ។

ដានី ៖ បងប្អូន៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

គា ៖ ស្រី៣ ប្រុស៣ ។

ដានី ៖ ស្រី៣ ប្រុស៣ចុះមីងកូនទីប៉ុន្មាន?

គា ៖ ខ្ញុំកូនទី៣

ដានី ៖ កាលពីក្មេងៗមីងបានរៀនសូត្រអីដល់ណាដែរ?

គា ៖ រៀនថ្នាក់ទី៩ ។

ដានី ៖ រៀនថ្នាក់ទី៩នៅសាលាណា?

គា ៖ សាលាព្រះនេទ្រព្រះយើងហ្នឹង ។

ដានី ៖ សាលាព្រះនេត្រកាលហ្នឹងគេហៅសាលាអីគេ សាលាបឋមសិក្សាអី?

គា ៖ សាលាព្រះនេត្រព្រះហ្នឹង?

ដានី ៖ បាទ!កាលហ្នឹងមានពីថ្នាក់ទីប៉ុន្មានដល់ទីប៉ុន្មានទៅ?

គា ៖ កាលហ្នឹងមានត្រឹមថ្នាក់ទី១០ ។

ដានី ៖ ពីថ្នាក់ទី១២ដល់ថ្នាក់ទី១០?

គា ៖ ចា៎!

ដានី ៖ ប៉ុន្តែមីងថាមីងបានរៀនថ្នាក់ទី៩?

គា ៖ ទី៩ ប៉ុន្តែយើងរៀនថ្នាក់ទី១ ទី២ ថ្នាក់ទី១២ដែលយើងថាស្រះអ ស្រះអាអីណា៎ ។

ដានី ៖ បាទ!ថ្នាក់ទី១២ ទី១០ ទី៩អញ្ចឹង?

គា ៖ ចាំ!

ដានី ៖ អញ្ចឹងថ្នាក់ធំជាងគេបំផុតមានដល់ថ្នាក់ទីប៉ុន្មានទៅ?

គា ៖ ថ្នាក់ធំកាលហ្នឹង មិនដឹងដល់ថ្នាក់ទីប៉ុន្មានទេ ដល់វាចាស់ទៅវាភ្លេចភ្លាំង ។

ដានី ៖ ប៉ុន្តែនៅសាលាព្រះនេត្រព្រះហ្នឹង រៀនដល់ត្រឹមណាបានអស់ថ្នាក់រៀន?

គា ៖ ដល់ថ្នាក់ទី១០ ទី១០រួចបានទៅជប់ ប្រឡងជប់ណាំ ។

ដានី ៖ អញ្ចឹងមីងបានប្រឡងដែរ?

គា ៖ អត់ទេ ។

ដានី ៖ អញ្ចឹងមីងរៀនបានដល់ថ្នាក់ទីប៉ុន្មានទៅ?

គា ៖ ទី៩ហ្នឹងឯង ។

ដានី ៖ ថ្នាក់ទី៩ អញ្ចឹងមីងថាថ្នាក់ទី១០គេប្រឡង អញ្ចឹងមីងរៀនហួសថ្នាក់ទី១០ ព្រោះទី១០ហើយបានទី៩?

គា ៖ ទី៩ហើយបានទី១០កាលសម័យកាលហ្នឹង ។

ដានី ៖ ទី៩ហើយបានទី១០?

គា ៖ ចាំ!

ដានី ៖ អញ្ចឹងមានថ្នាក់ទី១ ទី២ ទី៣ ទី៤មានដល់ទី៩ហើយបានទី១០?

គា ៖ ចាំ! រួចបានចប់ហ្នឹងគេឲ្យទៅរៀននៅស្វាយ អ៊ុះ!ប្រឡងជាប់កាលហ្នឹង ។

ដានី ៖ បាទ!មីងអត់ទាន់បានប្រឡងទេ?

គា ៖ អត់ទាន់បានប្រឡងទេ ។

ដានី ៖ មីងរៀនបាន៩ឆ្នាំដែរ ពីសម័យណាហ្នឹង?

គា ៖ កាលពីសម័យលន់ ណុល សម័យប៉ុន្មានកាលហ្នឹង ។

ដានី ៖ មីងឈប់រៀនឆ្នាំណា?

គា ៖ ឈប់រៀនមិនដឹងឆ្នាំណាទេ ព្រោះអ្នកស្រែយើងមិនបានជាម៉ត់ចត់ ។

ដានី ៖ ឈប់រៀនមុនរដ្ឋប្រហារឬក៏ក្រោយរដ្ឋប្រហារ រដ្ឋប្រហារឆ្នាំ៧០?

គា ៖ មុនៗ ។

ដានី ៖ មុនឆ្នាំ៧០ទៀតអញ្ចឹង?

គា ៖ ចាំ!

ដានី : ឈប់បានប៉ុន្មានឆ្នាំបានរដ្ឋប្រហារ?

គា : ខ្ញុំឈប់បាន៤ឆ្នាំ គេរដ្ឋប្រហារ ។

ដានី : បាទ!ពេលឈប់រៀនហើយមីងធ្វើអីទៀតទៅ?

គា : ធ្វើស្រែ ។

ដានី : បាទ!កាលហ្នឹងធ្វើស្រែនៅណា?

គា : ធ្វើស្រែនៅវាលខាងកើតហ្នឹង ។

ដានី : កាលហ្នឹងធ្វើស្រែជាមួយឪពុកម្តាយឬក៏?

គា : ចា៎! ធ្វើជាមួយឪពុកម្តាយ ។

ដានី : បាទ!ធ្វើស្រែដល់ពេលណាទៅបានឈប់?

គា : អត់ទេ!ធ្វើមកទល់ដល់សព្វថ្ងៃនេះ ។

ដានី : បាទ!ប៉ុន្តែមីងធ្វើស្រែជាមួយឪពុកម្តាយដល់ពេលណា បានមីងឈប់ធ្វើស្រែទៅធ្វើអីទៀតទៅ?

គា : ឈប់ធ្វើស្រែជាមួយម្តាយខ្ញុំនៅពេលដែលយួនចូលហើយហ្នឹង ។

ដានី : បាទ! ចុះមីងពេលដែលបែកភ្នំពេញឆ្នាំ៧៥ ពេលដែលអាពតចូលម៉ោហ្នឹង កាលពីមុនហ្នឹងមីងនៅធ្វើស្រែជាមួយឪពុកម្តាយរហូត?

គា : ចា៎!ធ្វើរហូត ។

ដានី : ធ្វើរហូតដល់ពេលទល់អាពតចូល?

គា : ចា៎!

ដានី : ដល់ពេលអាពតចូលឆ្នាំ៧៥ហ្នឹង យ៉ាងម៉េចទៀតទៅមីងអាចរៀបរាប់?

គា : ដល់អាពតចូលម៉ោខ្ញុំចល័តរហូតទៅ ។

ដានី : មីងចូលកងចល័តតាំងពីឆ្នាំណាទៅ?

គា : មិនដឹងឆ្នាំណាទេ មិនដឹងអាពតឆ្នាំណាបានចេះគិត បានចេះពិចារណាទេ ។

ដានី : អញ្ចឹងអាពតម៉ោភ្លាមធ្វើកងចល័តភ្លាមហ្មង?

គា : ចា៎!

ដានី : គេធ្វើកងចល័តហ្នឹងយ៉ាងម៉េចមីង យើងស្ម័គ្រចិត្តចូលកងចល័តឬក៏គេម៉ោចាត់តាំងបង្ខំឲ្យយើងចូល?

គា ៖ គេចាត់តាំងនាង គេចាប់យើងទៅរែកដីរែកអី យើងគ្មានហានទេ បើគេឲ្យយើងទៅ យើងត្រូវតែទៅ ។

ដានី ៖ កងចល័តហ្នឹងគេហៅកងចល័តអីទៅមីងកាលហ្នឹង?

គា ៖ អាហ្នឹងគេហៅកងចល័តអីទេខ្ញុំភ្លេចហើយ ។

ដានី ៖ បាទ!ប៉ុនកាលហ្នឹងគេកហៅកងចល័តភូមិ កងចល័តឃុំ ឬក៏កងចល័តស្រុក ។

គា ៖ កងចល័តឃុំ ។

ដានី ៖ កងចល័តឃុំ?

គា ៖ ចាំ!

ដានី ៖ គេហៅឃុំអីកាលហ្នឹង?

គា ៖ ឃុំព្រះនេត្រព្រះយើងហ្នឹងឯង ។

ដានី ៖ បាទ! កាលហ្នឹងកងចល័តហ្នឹងមានស្រី មានប្រុសឬក៏មានតែស្រីៗទេ?

គា ៖ ស្រីផង ប្រុសផងទាំងអស់ហ្នឹងមាំតំបន់យើងហ្នឹង មាំតំបន់៥ហ្នឹងទៅជុំគ្នាទាំងអស់ ត្រពាំងថ្ម ។

ដានី ៖ មានស្រី មានប្រុសអាយុប្រហែលប៉ុន្មានទៅកងចល័តហ្នឹង?

គា ៖ បើយើងនៅក្មេងគេឲ្យទៅ បើអ្នកណាអាយុមិនទាន់៣០អីទេគេឲ្យទៅ ។

ដានី ៖ បាទ!ប៉ុន្តែក្នុងកងចល័តរបស់មីង ដែលមីងចាប់ពីឆ្នាំ៧៥ទៅមិនចូលក្នុងកងចល័ត?

គា ៖ ចាំ!

ដានី ៖ បាទ!កងចល័តហ្នឹងយើងចំរុះគ្នាមានចាស់ មានក្មេងឬក៏តែក្មេងៗទេ?

គា ៖ ទេ!មានចាស់មានក្មេងដែរ បើអ្នកស្រុកអ្នកមូលដ្ឋានយើងនេះ មានអ្នកភូមិមួយចំនួន ដែលខ្ញុំអាយុត្រឹម២៥អី អាយុ២០គត់អីមាន បើថាអ្នកថ្មីអីអាយុ៣០ ។

ដានី ៖ បាទ!តែអ្នកនៅលីវឬក៏មានប្ដីប្រពន្ធហើយ?

គា ៖ សុទ្ធតែលីវទាំងអស់ បើអ្នកថ្មីបានមានប្ដីមានប្រពន្ធ ។

ដានី ៖ សុទ្ធតែអ្នកនៅលីវ?

គា ៖ ចាំ!

ដានី ៖ ហើយបើប្រជាជនថ្មីអ្នកមានប្ដី មានប្រពន្ធហើយគាត់អត់ចូលកងចល័តទេ?

គា ៖ មាន ពួកមានគ្រួសារគេហៅកងអីទេភ្លេចបាត់ហើយ ។

ដានី ៖ បាទៗ!ចុះកាលហ្នឹងមីងអាយុប៉ុន្មាន ចូលកងចល័តមុនដំបូង?

គា ៖ ចូលកងចល័តមុនដំបូងខ្ញុំអាយុ២២ ។

ដានី ៖ ចុះកាលហ្នឹងគ្នាប៉ុន្មាននាក់ទៅកងចល័តឃុំព្រះនេត្រព្រះ?

គា ៖ កងចល័តឃុំព្រះនេត្រព្រះច្រើនណាស់ខ្ញុំមិនដឹងប៉ុន្មាននាក់ទេ ព្រោះខ្ញុំកូនក្រុមយើងនៅតែក្រោមបញ្ជាគេ បើមាក្រុមខ្ញុំនេះមាន១០នាក់ ។

ដានី ៖ មួយក្រុម១០នាក់?

គា ៖ ចា៎!មួយក្រុម១០នាក់ៗ ។

ដានី ៖ ចុះមានប៉ុន្មានក្រុមទៅនៅឃុំព្រះនេត្រព្រះហ្នឹង?

គា ៖ មិនដឹងមានប៉ុន្មានក្រុមទេខ្ញុំភ្លេចបាត់អស់ហើយ ។

ដានី ៖ ចុះប្រធានកងចល័តឃុំព្រះនេត្រព្រះឈ្មោះអី ពេលដែលមីងចូលឆ្នាំ៧៥ហើយ ដំបូងបំផុត ។

គា ៖ ស្គាល់តែអ្នកគេម៉ោពីថ្មី ដូចថាមានអីនៅស្រុក ដូចអ្នកព្រៃមាន់ចេះយកមកកាន់ក្តាប់ខ្ញុំឈ្មោះ បឿន មិនដឹងគាត់នៅណាណីទេណា៎!គាត់មកកាន់ក្តាប់ឃុំហ្នឹង ។

ដានី ៖ គណៈឃុំ?

គា ៖ ចា៎!

ដានី ៖ គណៈឃុំហ្នឹងប្រធានកងចល័តហ្នឹងដែរ?

គា ៖ ចា៎! គេហៅចលនាឃុំ ។

ដានី ៖ អញ្ចឹងពេលមីងចូលកងចល័តដំបូង នៅឃុំព្រះនេត្រព្រះហ្នឹងគេឲ្យធ្វើអីខ្លះទៅមេដឹកនាំគេ?

គា ៖ មុនដំបូងគេឲ្យទៅនៅភ្នំលាភយើងនេះ គេឲ្យស្ទូង ពេលស្ទូងរួចអីរួចគេដាក់ផែនការណ៍ឲ្យទៅលើកទំនប់ ។

ដានី ៖ កាលនៅភ្នំលាភហ្នឹងស្ទូងទៀត?

គា ៖ ចា៎!ស្ទូង ។

ដានី ៖ ស្ទូងហ្នឹងមានផែនការណ៍អីដែរឬអត់?

គា ៖ អត់មានផែនការណ៍ទេ គិតតែស្ទូង ។

ដានី ៖ គិតែស្ទូង កាលហ្នឹងស្ទូងគ្នាច្រើនទេ?

គា ៖ ច្រើនប្រហែល៥០នាក់ ។

ដានី ៖ កាលហ្នឹងហូបចុកអីយ៉ាងម៉េចដែរ?

គា ៖ ហូបចុកបរបូរណ៍កាលហ្នឹង ។

ដានី ៖ ហើយម៉េចទៀតទៅ ស្ទូងហ្នឹងរយៈពេលប៉ុន្មានទៅ?

គា ៖ ដល់ស្ទូងគេហៅកាលហ្នឹងស្រែប្រាំង៣ខែ ដូចច្រូតទៅគេស៊ីបរបូរណ៍ ។

ដានី ៖ អញ្ចឹងខែប្រាំងស្ទូង?

គា ៖ ខែប្រាំង អត់មានខែប្រាំងស្ទូងទេ ខែវស្សាហ្នឹងគេស្ទូង ដល់ពេលនេះខ្ញុំទៅធ្វើបាន ប្រហែលជាមួយខែ បានគេដាក់ផែនការណ៍ឲ្យយើង ក្មេងៗទៅលើកដីនៅភ្នំថ្ម ភ្នំស្រុក យើងនេះណា៎ តែខ្ញុំខានកូនក្មេងទៅលើកទំនប់ហ្នឹង ។

ដានី ៖ អញ្ចឹងមីងទៅលើកទំនប់ បន្ទាប់ពីនៅភ្នំលាភហ្នឹងបាន៣ខែ គេចាត់ឲ្យទៅលើកទំនប់ ទៀត?

គា ៖ ចា៎!

ដានី ៖ ខាងណាទៅដែលគេចាត់ឲ្យទៅលើកទំនប់ នៅខែណាឆ្នាំណាហ្នឹង?

គា ៖ កាលហ្នឹងមិនដឹងជាឆ្នាំណាមិនបានពិចារណា មិនបានគិតអី គិតតែថាគេប្រើហើយ យើងចេះតែទៅ គ្មានបានទៅគិតណា ។

ដានី ៖ បាទ!អញ្ចឹងពេលដំបូង ពេលឆ្នាំ៧៥ដំបូងគេឲ្យទៅស្ទូងនៅភ្នំលាភ?

គា ៖ ចា៎!

ដានី ៖ ដល់ពេល៣ខែក្រោយម៉ោ អញ្ចឹងនៅក្នុងឆ្នាំ៧៥ដដែល ឬក៏នៅឆ្នាំណាទៅ?

គា ៖ ខែប្រាំងខែវស្សាហ្នឹងនាង អត់មានអីទេ គេប្រើងយើងដឹងថាយើងធ្វើកើត ។

ដានី ៖ ប៉ុន្តែមីងទៅមុនដំបូង?

គា ៖ ទៅមុនដំបូងខែ មិនដឹងជាខែណាមិនបានទៅពិចារណាទេនាងអើយ ។

ដានី ៖ ប៉ុន្តែមីងអាចចាំបានថាពេលហ្នឹងជាខែប្រាំង ឬក៏ខែវស្សា?

គា ៖ ខែប្រាំង ។

ដានី ៖ អញ្ចឹងមីងទៅស្ទូងទៀតនៅខែវស្សា?

គា ៖ ចា៎!ខែវស្សា ខែនេះឯង ។

ដានី ៖ កាលគេបញ្ជូនទៅលើកទំនប់ហ្នឹងគេហៅទំនប់អីទៅ?

គា ៖ គេហៅទំនប់ត្រពាំងថ្ម ។

ដានី ៖ កាលហ្នឹងបញ្ជូនទៅគាប៉ុន្មាននាក់?

គា ៖ អ៊ូ!គ្នាច្រើនណាស់ទៅម៉ាតំបន់៥ យើងទៅទាំងអស់ រាប់ពាន់នាក់ ។

ដានី ៖ កាលហ្នឹងម៉េចមីងដឹងថាគេបញ្ជូនទៅម៉ាតំបន់៥?

គា ៖ ចាំ!ម៉ាតំបន់៥ ។

ដានី ៖ អញ្ចឹងក្នុងកងចល័តរបស់មីងនៅឃុំព្រអនេត្រព្រះហ្នឹងទៅទាំងអស់?

គា ៖ ទៅទាំងអស់ សុទ្ធតែអ្នកនៅលីវៗយើងហ្នឹង គេឲ្យទៅទាំងអស់ ។

ដានី ៖ កាលហ្នឹងពីណាប្រាប់ថាម៉ាតំបន់៥ គេបញ្ជូនទៅទាំងអស់?

គា ៖ ចុះនៅជុំគ្នាទាំងអស់ហ្នឹង ។

ដានី ៖ អញ្ចឹងពីដំបូងពីណាគេជាអ្នកដឹកនាំយើងទៅលើកទំនប់?

គា ៖ ឈ្មោះយាយ ថែម ៗអ្នកខេត្តតាកែវគេម៉ោកាន់ក្តាប់ ។

ដានី ៖ ចុះមីងទៅលើកទំនប់ហ្នឹងយាយ ថែម គាត់ម៉ោហើយ ឬក៏មុនយាយ ថែម ម៉ោ ទៀត?

គា ៖ ម៉ោហើយជុំគ្នា យាយថែម មិនដឹងគាត់ម៉ោពីអន្លង់ណា ពុថាឈ្មោះយាយថែមៗ ទៅគាត់ម៉ោកាន់ក្តាប់មើលយើងធ្វើការ រួចដល់នេះក៏មានថ្នាក់ក្រោមទៀតដូចថាប្រ ធាន អនុប្រធានអញ្ចឹងទៅណា ឈ្មោះតាអីទេ ភ្លេចទៅនាងដល់វាយូរពេកទៅវាមិនបានពិចារណានោះឯង ។

ដានី ៖ ប៉ុន្តែកាលទៅដំបូង កាលទៅភ្នំលាកភ្នំអីហ្នឹង កាលហ្នឹងពុឈ្មោះយាយថែម ឬនៅ?

គា ៖ មាន កាលហ្នឹងគេហៅពួកនិរតី មកកាន់កាប់យើងតំបន់៥ ពួកដែលចាស់នោះគេយកវ៉ៃចោលអស់ហើយ ពួកក្នុងភូមិនេះមានប្រធានភូមិចេះ ដល់អាពួកនោះគេមានខាងតំបន់៥គេម៉ោ ខាងនេះគេម៉ោចេះយកគាត់ហ្នឹងទៅវ៉ៃចោលទៅ គេម៉ោកាន់ក្តាប់យើងជាថ្មី យើងអ្នកមូលដ្ឋានដែលធ្វើប្រធានភូមិប្រធានអីនេះដូចតា ឌឹម សព្វថ្ងៃគេហៅប្រធានភូមិ គេហៅអីទេខ្ញុំមិនបានពិចារណាអីទេ ធ្វើម៉េចសុំតែម៉ារស់ឲ្យតែគេថានេះ ទៅគេយកទៅវ៉ៃចោលអស់ ។

ដានី ៖ មីងពេលដែលយើងបែកឆ្នាំ៧៥ម៉ោ កាលហ្នឹងពួកនិរតីអត់ទាន់ម៉ោទេ កាលពីថ្មីៗជម្លៀសម៉ោភ្នំពេញដំបូង?

គា ៖ ម៉ោហើយ ។

ដានី ៖ នរតីម៉ោឬនៅ?

គា ៖ ម៉ោហើយ និរតីម៉ោហើយ ម៉ោមុនៗអ្នកជម្លៀស ម៉ោបានប្រហែល២ខែបានគេជម្លៀសមានអ្នកថ្មីម៉ោ ។

ដានី ៖ បាទ!ជម្លៀសពួកអ្នកថ្មីម៉ោ?

គា ៖ ចាំ!

ដានី ៖ បាទ! ប៉ុន្តែមីងមានប្រសាសន៍មិញថា ពួកនិរតីម៉ោបានគេសម្លាប់កម្មាភិបាលចាស់ៗ អ្នកដឹកនាំនៅហ្នឹង?

គា ៖ ចាំ!

ដានី ៖ អញ្ចឹងពួកកម្មាភិបាលចាស់ហ្នឹងគេដឹកនាំតាំងពីអន្កាល់ណា?

គា ៖ កាលពី៧៥ កាលដែលពួកអាពតចូលហ្នឹងឯង ។

ដានី ៖ អូ!ពួកអាពតចូលម៉ោហ្នឹង ពួកកម្មាភិបាលចាស់គ្រប់គ្រង?

គា ៖ ចាំ!ពួកដែលភូមិយើងចេះ អត់មានភូមិម្ខាងចេះអត់សោះ អនុប្រធាន ប្រធានគេម៉ោពីកើត ម៉ោពីខេត្តសៀមរាបគេម៉ោកាន់ក្តាប់យើងអ្នកមូលដ្ឋាននេះធ្វើជាអនុគេណា ដល់នេះទៅគេវ៉ៃចោលអស់ទៅ ។

ដានី ៖ បាទ!អញ្ចឹងពេលដែលអាពតចូលម៉ោដំបូងមានធ្វើកងចល័តឬនៅ?

គា ៖ អត់ទាន់ធ្វើទេ នៅជុំចាស់ៗ ។

ដានី ៖ នៅជុំចាស់ៗ?

គា ៖ ចាំ!ដាំដំឡូងដាំអីណា ។

ដានី ៖ អូ!អញ្ចឹងកាលពេលដែលមីងថាពួកអាពតចូល ហើយម៉ោពីព្រៃមានម៉ោពីអីផ្សេងដែលពួកកម្មាភិបាលនេះ កាលហ្នឹងយើងអត់ទាន់បានធ្វើកងចល័តទេ?

គា ៖ នៅ អត់ទាន់បានធ្វើទេ ។

ដានី ៖ ដល់ពេលណាបានធ្វើកងចល័ត?

គា ៖ ពួកនិរតីម៉ោហ្នឹងឯង ។

ដានី ៖ អូ!ពួកនិរតីម៉ោ?

គា ៖ ចាំ!

ដានី ៖ មីងអត់ចាំឆ្នាំពួកនិរតីម៉ោទេ?

គា ៖ អត់ទេ!អត់បានចាំទេ ។

ដានី ៖ ចុះពួកដែលថាកម្មាភិបាលចាស់ៗដែលគាត់ម៉ោ កម្មាភិបាលមីងនិយាយមិញថាម៉ោពីព្រៃមាន់ កម្មាភិបាលក្នុងស្រុកភូមិហ្នឹងគាត់អ្នកដឹកនាំដំបូងបានប៉ុន្មានឆ្នាំទៅ បានពួកនិរតីម៉ោ?

គា ៖ បានប៉ុន្មានប្រហែលជា២ឆ្នាំ ៣ឆ្នាំខ្ញុំមិនបានដាពិចារណាទៀត ។

ដានី ៖ ដល់ពេលពួកនិរតីម៉ោ គេចាប់ពួកកម្មាភិបាលចាស់ៗហ្នឹង?

គា ៖ ចាំ!យកទៅវៃចោល ។

ដានី ៖ ចុះមីងម៉េចដឹងថាគេចាប់យកទៅវៃចោល?

គា ៖ ចុះបើវៃចោលមែន ឃើញទាំងសេៗ ។

ដានី ៖ ហ៊ឺ!គេវៃចោលនៅណាទៅ?

គា ៖ វៃចោលឯណាទេនាង ។

ដានី ៖ ដល់ពេលនិរតីម៉ោបានគេវៃចោល ឬគេវៃចោលតាំងពីពួកនិរតីមិនទាន់ម៉ោ?

គា ៖ ទេដែលពួកនិរតីចូលម៉ោហ្នឹងឯង ។

ដានី ៖ កាលហ្នឹងមីង អ្នកដែលនិរតីចូលម៉ោហ្នឹងមីងចាំឈ្មោះពីណាខ្លះ?

គា ៖ មិនចាំទេ យូរទៅមិនបានជាចាំពិចារណាទេ ឈ្មោះអីៗចាំបានដែរ ចុះគេមាននៅស្រុកយើងនេះ នៅតាកែវ នៅព្រៃវែងអីណា នៅកំពតអីណានោះ ។

ដានី ៖ បាទៗ!កាលហ្នឹងដំបូងមីងមីងថាឈ្មោះ បឿនអញ្ចឹង?

គា ៖ ចាំ!

ដានី ៖ បឿន ហ្នឹងគាត់អ្នកម៉ោពីព្រៃមាន់?

គា ៖ ទេ គាត់មិនដឹងនៅណាទេ គាត់នៅម៉ាជួរយើងទៅក្រោមហ្នឹងឯង ។

ដានី ៖ បាទ!បឿន ហ្នឹងគាត់ជាកម្មាភិបាលចាស់ទេ មិនមែនពួកអ្នកម៉ោពីនិរតីទេ?

គា ៖ បន្ទាប់គ្នានឹងពួកនិរតីហ្នឹងឯង ដូចកាន់មុននិរតី ។

ដានី ៖ កាន់មុននិរតី?

គា ៖ ចាំ! ដល់គេធ្វើការល្អគេមិនសម្លាប់ ដល់មិនសម្លាប់ចោលគាត់ធ្វើប្រធានភូមិ ធ្វើម៉ាភូមិនោះគេវៃចោល ។

ដានី ៖ កាលហ្នឹងឈ្មោះបឿន គាត់គណៈឃុំ កាលហ្នឹងគណៈស្រុកឈ្មោះអីទៅជំនាន់ដំបូងកាលពេលអាពតចូលដំបូង?

គា ៖ ឈ្មោះ តាក្រុក ។

ដានី ៖ ឈ្មោះ តាក្រុកហ្នឹងចៅហ្វាយស្រុកព្រះនេត្រព្រះ?

គា ៖ ចាំ!

ដានី ៖ តាក្រុកហ្នឹងអ្នកស្រុកណា?

គា ៖ មិនដឹងនៅស្រុកណាទេ ឮគេថាអ្នកស្រុកកើតៗមិនដឹងជាស្រុកណាស្រុកណីទេ ។

ដានី ៖ អ្ហូ!អត់ដឹងទេ?

តា ៖ អត់ដឹងទេ ។

ដានី ៖ បាទ!តាក្រក ហើយពីណាទៀតអ្នកដែលធ្វើគណៈស្រុក ដូចជាមានគ្នា២-៣នាក់អញ្ចឹង មានតាក្រក មានពីណាទៀត?

តា ៖ មិនដឹងពីណាទៀតខ្ញុំស្គាល់តែតាក្រក ព្រោះគាត់មកកាន់ក្តាប់ខ្ញុំផ្ទាល់ ។

ដានី ៖ តាក្រកហ្នឹងគាត់គណៈស្រុក ម៉ាស្រុកព្រះនេត្រព្រះហ្នឹង?

តា ៖ ម៉ាឃុំៗព្រះនេត្រព្រះយើង ។

ដានី ៖ ម៉ាឃុំព្រះនេត្រព្រះ មុនឈ្មោះ បឿនហ្នឹងទៀត?

តា ៖ បឿន ហ្នឹងគេហៅចលនា ពីដើមឡើយគេហៅចលនាដើរចល័តមកបង្រួបបង្រួមយើង បងប្អូនហ្នឹងឲ្យធ្វើការងារ ធ្វើអីៗទៅ ។

ដានី ៖ បាទ!ហើយតាក្រក ហើយតាបឿនហ្នឹងធ្វើការជាមួយគ្នាអញ្ចឹង?

តា ៖ ចា៎

ដានី ៖ ប៉ុន្តែតាក្រកធំជាងបឿន?

តា ៖ ចា៎!

ដានី ៖ អញ្ចឹងតាក្រក គាត់គណៈឃុំព្រះនេត្រព្រះឬក៏គណៈស្រុក?

តា ៖ អត់មានទេ គណៈឃុំ ។

ដានី ៖ គណៈឃុំទេ?

តា ៖ ចា៎!

ដានី ៖ ចុះគណៈស្រុក?

តា ៖ គណៈស្រុកមិនដឹងឈ្មោះអីទេនាង ដល់នៅឆ្ងាយអញ្ចឹង ខ្ញុំដើរឆ្លងពីភូមិមួយទៅស្រុកមួយហ្នឹង យើងនៅភូមិណាដឹងតែនៅភូមិហ្នឹង ។

ដានី ៖ បាទ!អញ្ចឹងកាលមុន កាលតាក្រក តាបឿនអីហ្នឹងមីងមិនទាន់ទៅធ្វើកងចល័តទេ?

តា ៖ អត់ទាន់ធ្វើទេ ទល់តែនិរតីម៉ោបានធ្វើកងចល័ត ។

ដានី ៖ កាលហ្នឹងអត់ទាន់លើកទំនប់ត្រពាំងថ្មទេ ឬលើកឬនៅ?

តា ៖ អត់ទាន់លើកទេកាលនោះ ។

ដានី ៖ អត់ទាន់លើកទេ?

តា ៖ ចា៎!

ដានី ៖ ពេលពួកនិរតីម៉ោកាលហ្នឹង ម៉ោធ្វើគណៈព្រះនេត្រព្រះហ្នឹងឈ្មោះអីទៅ?

គា ៖ ខ្ញុំមិនដែលហ៊ានសួរនាំ មិនដែលហ៊ានដឹងទេខ្លាចៗ

ដានី ៖ ចុះមីងមានប្រសាសន៍ថាឈ្មោះ យាយចែមៗនោះ?

គា ៖ យាយចែមហ្នឹង ទាល់តែខ្ញុំទៅនៅចល័តត្រពាំងថ្មហ្នឹង បានគាត់ឡើងបើកសន្និបាតគេថាប្រជុំហ្នឹង ដល់សម័យនោះគេហៅសន្និបាត ហៅពួកចល័តទាំងអស់ទៅប្រជុំបង្រួបបង្រួមបណ្ដុះរឹងគល់ដំហរខំធ្វើការងារ ហ្នឹងបានគេថាយាយចែមៗ ស្គាល់តែយាយចែមៗហ្នឹង ប៉ុនមិនដែលស្គាល់មុខទេណា៎ ឮតែឈ្មោះៗ

ដានី ៖ យាយចែម គាត់ធ្វើអីកាលហ្នឹង?

គា ៖ ធំណាស់នាង លើបញ្ជាលើគាត់ទាំងអស់ៗ

ដានី ៖ ធំ?

គា ៖ ចា៎!

ដានី ៖ បញ្ជាលើគាត់ទាំងអស់ បញ្ជានៅកន្លែងណាខ្លះទៅ?

គា ៖ នៅតំបន់ដែលយើងធ្វើកាលសម័យអាពតគឺគាត់ហ្នឹងហើយអ្នកកាន់កាប់ៗ

ដានី ៖ គាត់តំបន់៥ដែរ?

គា ៖ ចា៎!តំបន់៥យើងហ្នឹងគាត់អ្នកប្លូរផ្ដាច់ៗ

ដានី ៖ ដែលឃើញមុខគាត់ឬអត់?

គា ៖ មិនដែលឃើញទេ ឮតែគេថា បើយើងប្រជុំគ្នា គាត់នៅនោះ យើងនៅនេះចុះបើគ្នាច្រើននោះនាងៗ

ដានី ៖ បាទ!អញ្ចឹងមីងពេលដែលទៅលើកទំនប់ត្រពាំងថ្មហ្នឹង ដំបូងគេចាត់ឲ្យមីងនៅកន្លែងណាធ្វើម្ដុំណាអីយ៉ាងម៉េចខ្លះទៅ?

គា ៖ ខ្ញុំកាលដែលខ្ញុំទៅធ្វើចល័តខ្ញុំនៅស្អី នៅភូមិណាំតៅៗ

ដានី ៖ នៅភូមិណាំតៅ?

គា ៖ ចា៎!

ដានី ៖ ណាំតៅហ្នឹងនៅកន្លែងណាទៅ?

គា ៖ មិនដឹងនៅកន្លែងណាទេនាង ដល់ទៅអញ្ចឹងទៅគេស្គាល់គេថានេះជាភូមិណាំតៅ ក៏ណាំតៅគេទៅ គ្រាន់តែដឹងថាមិនមែននៅក្បែរភូមិទេ នៅកណ្ដាលព្រៃធំដើមឈើប៉ុនៗណាណី ៗ

ដានី ៖ មានគ្នាប៉ុន្មាននាក់ទៅកាលហ្នឹងនៅណាំតៅ?

គា ៖ អ៊ូ! ច្រើនណាស់ មនុស្សចូលរាប់ពាន់ ។

ដានី ៖ អាហ្នឹងអ្នកគ្រប់គ្រងមីងនៅនោះឈ្មោះអី?

គា ៖ ដូចខ្ញុំថាអញ្ចឹងឈ្មោះ បឿន ហ្នឹងឯង ។

ជិតខាង ៖ មនុស្សលើកទំនប់ត្រពាំងថ្មូ ។

ដានី ៖ ឈ្មោះ បឿនគាត់ក្តាប់ម៉ាអីទៅ?

គា ៖ ក្តាប់ម៉ាចល័តនោះឯង ។

ដានី ៖ ម៉ាចល័តណា?

គា ៖ ម៉ាចល័តដែលពួកខ្ញុំទៅនេះ ទៅពួកនារីទៅចល័តប៉ុន្មានគាត់ហ្នឹងហើយអ្នកកាន់កាប់ ។

ដានី ៖ កាន់ម៉ានារីពីណាទៅ ពី?

គា ៖ ពីឃុំព្រះនេត្រព្រះយើងនេះ ។

ដានី ៖ ពីឃុំព្រះនេត្រព្រះនេះ?

គា ៖ ចា៎!

ដានី ៖ ចុះតាក្រក?

គា ៖ តាក្រកក៏នៅដូចគ្នាឯង ឃុំម៉ាឃុំព្រះនេត្រព្រះនេះក៏តាក្រក ប៉ុនតាក្រកគាត់មើលបាន ច្រើនជាអ្នកពួកចល័តទេ ពួកចលនាដូចថាឈ្មោះ បឿន អីទៅកាន់កាប់ពួកខ្ញុំ ។

ដានី ៖ អ៊ូ! តាបឿនគាត់កាន់កាប់ដែរ?

គា ៖ ចា៎! កាន់កាប់ ។

ដានី ៖ បាទ! អញ្ចឹងទៅលើកទំនប់ហ្នឹងដូចថាម៉ាថ្ងៃៗ យើងធ្វើការបានប៉ុន្មានទៅ?

គា ៖ ធ្វើការបើយើងម៉ាគីបចេះ បើយើងរួចម៉ាគីបតែមុងមួយឬមុងពីរចេះ គេតំឡើងម៉ាគីប កន្ទះ ដល់យើងធ្វើរួចទៅពីរគីប បើយើងធ្វើមិនរួចទល់តែម៉ោ១០យប់ ឬ១២យប់ យើងរួចស្មាលណាយើងម៉ោស្មាលហ្នឹងទៅ ។

ដានី ៖ អញ្ចឹងគេដាក់ផែនការណ៍ឲ្យយើងធ្វើ?

គា ៖ ចា៎! គេដាក់ផែនការណ៍ឲ្យធ្វើ ។

ដានី ៖ អញ្ចឹងមួយថ្ងៃយើងធ្វើបានទៅប៉ុន្មានគីប?

គា ៖ ទេបើគេអ្នកលើកបាន បើថាខ្ញុំម៉ាគីប ដល់ខ្ញុំលើកមិនរួចទៅគេត្រូវខ្ញុំឲ្យម៉ោដាំបាយ ។

ដានី ៖ អញ្ចឹងមីងក្នុងមួយថ្ងៃគេឲ្យលើកមួយគីប?

គា ៖ ចា៎!

ដានី ៖ ម៉ាគីបដូចថា យើងដឹកដីម៉ាគីបហ្នឹងទៅ?

គា ៖ វែកឡើងទំនប់ ទំបន់ហ្នឹងខ្ពស់ស្មើចុងដូង ។

ដានី ៖ ប្រហែលចុងដូង?

គា ៖ ចា៎!

ដានី ៖ យើងវែកពីក្រោម យើងដឹក?

គា ៖ វែកឡើងទៅ ។

ដានី ៖ វែកឡើងទៅ ប៉ុនកាលហ្នឹងមីងលើករួចឬអត់ម៉ាគីប?

គា ៖ ខ្ញុំអត់រួចទេ ម៉ាគីបព្រោះខ្ញុំជរាកាលដែលខ្ញុំត្រូវគ្រាប់ដើងនេះ គេអត់ឲ្យខ្ញុំលើក គេឲ្យត្រខ្ញុំម៉ោដាំបាយ ។

ដានី ៖ ត្រូវគ្រាប់ដើងម៉េច?

គា ៖ ត្រូវកាលអាពតវាបាញ់ចូល ពួកអាពតចូលម៉ោបាញ់នៅក្នុងភូមិ បាញ់ម៉ោត្រូវដើង ។

ដានី ៖ អាពតចូលបាញ់ម៉េចខ្ញុំអត់យល់?

គា ៖ អារៀបដែលរដ្ឋប្រហារនោះណា៎ វាចូលម៉ោដល់នេះវាចូលក្នុងភូមិវ៉ៃ ដល់នេះវា បាញ់ ។

ដានី ៖ ពួកវៀតណាមចូលឬក៏?

គា ៖ ទេ អាពតៗចូលវ៉ៃ ។

ដានី ៖ ចូលវ៉ៃជាមួយពីណា?

គា ៖ វ៉ៃជាមួយពួកទាហានខ្មែរយើងហ្នឹងឯង ចូលៗពេញនេះហ្នឹង ខ្លះចាប់អាលកវរចេញឈាមប្រោក ចូលបាញ់គ្នាម៉ាគរនរ ។

ដានី ៖ កាលមីងនៅទំនប់ត្រពាំងថ្មហ្នឹងមានត្រូវរបួសហើយឬនៅ?

គា ៖ ត្រូវរបួសហើយៗ បានវាជាបានវាចប់ ។

ដានី ៖ អ្ហូ!បានន័យថាមីងត្រូវរបួសតាំងពីមុនអាពតចូលទៀត?

គា ៖ មុន ។

ដានី ៖ អញ្ចឹងអាពតចូលឆ្នាំ៧៥?

គា ៖ ឆ្នាំ៧៥មិនដឹង ខ្ញុំមិនបានជាចំណាំ ។

ដានី ៖ បាទ!អញ្ចឹងពេលមីងទៅលើកទំនប់នៅត្រពាំងថ្មហ្នឹង កាលហ្នឹងត្រូវរបួសហើយ?

គា ៖ ចា៎!ត្រូវអាយុហើយ កាលហ្នឹងដូចអាយុ១៧-១៨ហើយ ។

ដានី ៖ កាលហ្នឹងម៉ាគីបលើកអត់ហើយទេ?

គា ៖ អត់ទេ!ដល់អញ្ចឹងទៅគេប្រើខ្ញុំឲ្យម៉ោដាំបាយ ។

ដានី ៖ គេអត់ថាអីទេ យើងលើកអត់រួចអញ្ចឹង?

គា ៖ គេអាណិត ដូចប្រធានភូមិយើងទៅរាយការណ៍ទៅថា គាត់នេះពិការជើងរែកមិនកើតអញ្ចឹងទៅ គេឲ្យយើងប្រើទៅដាំបាយ ។

ដានី ៖ លើកបានប៉ុន្មានខែបានគេប្រើឲ្យម៉ោដាំបាយវិញ?

គា ៖ ខ្ញុំលើកបានប្រហែលជាកន្លះខែ ក្នុងម៉ាគីបហ្នឹងទល់តែម៉ោង១២យប់នោះបានខ្ញុំរែក ។

ដានី ៖ ដល់ម៉ោង១២យប់បានរែក?

គា ៖ ចា៎! វាខ្ពស់ទំនប់ហ្នឹង ។

ដានី ៖ ចុះគេអ្នកផ្សេងៗទៀតគេលើកប៉ុន្មាន?

គា ៖ មុនដំបូងគេឲ្យម្នាក់ៗម៉ាគីបៗ ហើយលើកបានដល់ម៉ោង១០-១១អីរួច គេតំឡើងម៉ាគីបកន្លះ បើកងពិសេសគេ២គីប អាហ្នឹងកងពិសេសគេ ដូចពួកប្រុសៗកម្លាំងទី១ គេហៅកម្លាំងទី១ ។

ដានី ៖ ចុះកម្លាំងស្រីៗ អ៊ើ!កម្លាំងស្រីៗហ្នឹងដំបូងគេឲ្យម៉ាគីប ដល់ក្រោយម៉ោឲ្យម៉ាគីប កន្លះ?

គា ៖ ចា៎!

ដានី ៖ ដល់ពេល ចុះប្រុសៗ?

គា ៖ ប្រុសៗម៉ាគីបកន្លះដូចគ្នា បើកងពិសេសគេ២គីប ដូចអាគ្នារាងយ៉ាប់អាពួកអ្នកថ្មីស៊ីមិនបរបូរណ៍ទៅគ្នាយ៉ាប់ទៅ ជួនណាគ្នាបានម៉ាកំណាត់ៗទៅ ។

ដានី ៖ ចុះមីងអ្នកដាំបាយដាំអីហ្នឹងដូចថាអ្នកដាំបាយហ្នឹងរបបយ៉ាងម៉េចទៅ?

គា ៖ គេឲ្យអង្ករដូចថា១០នាក់អញ្ចឹង គេឲ្យអង្ករ៤០កំប៉ុងអញ្ចឹងព្រឹកល្ងាច យើងដាំបាយបិកៗទៅ ដាក់កូនចានចែកៗគ្នាទៅ ។

ដានី ៖ អញ្ចឹងក្នុង១០នាក់គេឲ្យ៤០កំប៉ុង?

គា ៖ ចា៎!

ដានី ៖ ៤០កំប៉ុងព្រឹកល្ងាច?

គា ៖ ចា៎!

ដានី ៖ អញ្ចឹងច្រើន៤០កំប៉ុង គ្នា១០នាក់ ក្នុង១ម្នាក់?

គា ៖ ទេ!នៅក្នុងដែលខ្ញុំដាំនោះវា៥ក្រុមណា៎នាង ។

ដានី ៖ ១៥ក្រុម?

គា ៖ ចាំ!៥ក្រុម ៤០កំប៉ុង ។
ដានី ៖ ៥ក្រុម៤០កំប៉ុង បានន័យថា៥ក្រុមហ្នឹងគ្នាប៉ុន្មាននាក់ ៥០នាក់?
គា ៖ ៥០នាក់ហ្នឹងអានាង ។
ដានី ៖ ៥០នាក់ ៤០កំប៉ុង?
គា ៖ ចាំ!
ដានី ៖ ៤០កំប៉ុងព្រឹកល្ងាច?
គា ៖ ចាំ!
ដានី ៖ អញ្ចឹងម្នាក់អត់ដល់មាំកំប៉ុងផង?
គា ៖ អត់បានទេ ។
ដានី ៖ ហូបឆ្អែតឬអត់អញ្ចឹង?
គា ៖ ចុះបើមិនឆ្អែតក៏ថាឆ្អែតដែរ អត់ហ៊ានថា ថាមិនឆ្អែតគេវ៉ៃចោលអានាង ។
ដានី ៖ អ្ហ៎!ថាមិនឆ្អែតគេវ៉ៃចោល?
គា ៖ ចាំ!
ដានី ៖ ចុះម្ហូបបានម្ហូបអីខ្លះ?
គា ៖ ម្ហូបមានប្រហុកៗមិនដឹងគេយកមកពីណាទេ យកមកចែកគ្នាទៅ ដាក់ទឹកឡើងរាវទៅ គ្នាមាំក្រុមប្រហុកមាំកូនចាន ។
ដានី ៖ ជាមួយប្រហុក?
គា ៖ ចាំ!ប្រហុកហ្នឹងអត់មានចិញ្ច្រាំអីទេ ស្ងោរទឹកប្រហុកដាក់ក្នុងមាំក្រុមអញ្ចឹង មាំកូនចាន ទៅ ឆ្អែតមិនឆ្អែតយើងថាឆ្អែតទៅ ៤-១០ថ្ងៃគេធ្វើការមើលថា អ្នកទាំងអស់គ្នាហូប ឆ្អែតទេ មិនឆ្អែតថាមិនឆ្អែតម៉េច ឆ្អែត ។
ដានី ៖ ចុះម្ហូបប្រហុករាល់តែថ្ងៃហ្នឹង អត់មានម្ហូបអីទេ?
គា ៖ ទេ!បើកន្លះខែអញ្ចេះទៅមានត្រីយកមកឲ្យ ក្បាលត្រីយកមកដាក់ស្ងោរ ថ្ងៃណាក្នុងមាំ ក្រុមអញ្ចឹងគេយកត្រីយកឲ្យប៉ុននេះទៅ ។
ដានី ៖ គេឲ្យក្បាលត្រី ក្បាលអីដែរ ប៉ុន្តែយូរៗមួយដងទេ?
គា ៖ ចាំ!យូរៗមួយម្ដង ។
ដានី ៖ ប៉ុន្តែក្រៅពីត្រី ក្រៅពីអីទៅប្រហុករហូតទៅ?

គា ៖ ប្រហុក កុំបានតែប្រហុកហូបទេនាង កុំតែបានប្រហុកកុំអីងាប់ហើយ បើបងប្អូនយើងអ្នកថ្មីគេជម្លៀសម៉ោ ដូចគ្នាហូបមិនឆ្អែតគ្នាទៅលួច គេចាប់បានគេវៃចោលត្រង់ហ្នឹង ។

ដានី ៖ លួចអីគេអាហ្នឹង?

គា ៖ លួចអំបិល លួចអីហ្នឹង ។

ដានី ៖ អញ្ចឹងដូចមិញហ្នឹងបាយគឺរហូត គឺ៤០កំប៉ុងហ្នឹង៥ក្រុមហ្នឹងគឺអត់មានលើសតាំងពីចូលលើក គេអត់មានលើសទេ?

គា ៖ រហូត ។

ដានី ៖ ហើយដំបូងគេឲ្យម៉ាម៉ែត្រ ដល់ពេលក្រោយម៉ោគេឲ្យម៉ាម៉ែត្រគីបកន្លះ?

គា ៖ ចា៎!

ដានី ៖ ចុះបើយើងលើកអត់រួចធ្វើម៉េចទៅ?

គា ៖ ធ្វើអីធ្វើទៅឲ្យតែរួច ធ្វើទាល់តែរួច អត់មានថាមិនរួចហើយយើងចូលទេ ទាល់តែរែកឲ្យរួច ។

ដានី ៖ ម៉ាម៉ែត្រគីបកន្លះហ្នឹងឲ្យរួចទៀត?

គា ៖ ឲ្យរួចអត់មានថា មិនរួចហើយឲ្យអ្នកឯងឡើងម៉ោ អត់ទេណា៎! អត់បានទេ ។

ដានី ៖ ពីណាអ្នកប្រាប់?

គា ៖ ប្រធានភូមិ ប្រធានក្រុមហ្នឹង ប្រធានក្រុមជាអ្នកស្តាប់បញ្ជាពីលើម៉ោទេ ហើយយើងត្រូវធ្វើតាម ។

ដានី ៖ កាលដំបូងគេឲ្យម៉ាម៉ែត្រ?

គា ៖ ចា៎!

ដានី ៖ មួយម៉ែត្ររយៈពេលប៉ុន្មានក្នុងមួយម៉ែត្រគីបហ្នឹង?

គា ៖ ប្រហែល១ខែ កាលហ្នឹង១ខែហើយបានគេគំឡើង គេឲ្យវៃសំរុកឲ្យខ្លាំងឲ្យឆាប់រួច ។

ដានី ៖ ដល់ពេលទៅលើករយៈពេលប៉ុន្មានទៅ?

គា ៖ អ៊ូ!អានាងយូរណាស់ប្រហែល ៥-៦ខែទៅដឹង យូរណាស់ ។

ដានី ៖ បាទ!ដល់ពេលហើយយើងត្រឡប់មកភូមិវិញ?

គា ៖ ចា៎!យើងអត់មានត្រឡប់ទៅទេ នៅកន្លែងគរ៣ដើមផ្លូវទៅភ្នំស្រុកហ្នឹង នៅកន្លែងត្រង់នោះឯងទៅធ្វើកងចល័ត ហ្នឹងម៉ាឃុំព្រះនេត្រព្រះយើងហ្នឹង ។

ដានី ៖ អ្ហូ! ពេលឈប់ហ្នឹង ម៉ោកន្លែងដើមគរពាដើមវិញ?

គា ៖ ចាំ! ធ្វើការដ្ឋានមួយនៅហ្នឹង ។

ដានី ៖ ធ្វើអីទៅហ្នឹង?

គា ៖ ធ្វើស្រែ ដកស្ទូងយើង ដកស្មៅដកអីទៅ ។

ដានី ៖ អញ្ចឹងមីងនៅបានប្រហែលជា៦-៧ខែបានគេផ្លាស់ឲ្យម៉ោកន្លែងគរពាដើមវិញ?

គា ៖ ចាំ!

ដានី ៖ នៅកន្លែងគរពាដើមបានប៉ុន្មានទៅ បានបែកឆ្នាំ៧៩ យួនចូល?

គា ៖ មិនដឹងខែប៉ុន្មាន ឆ្នាំប៉ុន្មានទេ ដល់នៅយូរទៅខ្ញុំស៊ូមិនបាន ខ្ញុំរត់ខ្ញុំរត់ម៉ោនៅក្នុងភូមិវិញ ស៊ូមិនបានខ្ញុំរត់ មើលទៅឃើញប្រធានភូមិគេឲ្យនៅធ្វើការកៀនចាស់ៗអញ្ចឹង ។

ដានី ៖ នៅបានយូរដែរបានបែក?

គា ៖ ចាំ! នៅបានគ្រាន់ដែរ ប្រហែលបាន២ខែ ៣ខែដែរនៅកន្លែងដើម ។

ដានី ៖ ចុះមីងកាលមីងលើកទំនប់នៅត្រពាំងថ្មអីហ្នឹង ក្នុងរយៈពេល៦-៧ខែហ្នឹង កាលហ្នឹង ដូចថា មីងមានដែលឃើញអ្នកលើកនៅជុំវិញ?

គា ៖ ទេ! គ្មានដើរទេនាងៗ គ្មានដើររហេរហូតទេវៃចោល ។

ដានី ៖ វៃចោល?

គា ៖ ចាំ! យប់ឡើងយើងដេកអញ្ចឹងមានគេយាមយើង កងឈ្លបគេយាម បើអ្នកណាមើលទៅមានពិរុទ្ធភាពថា មានបងប្អូនធ្វើទាហានទៅអីទៅ ធ្វើអ្នកធំចេះចាប់វៃចោលខ្ទិចខ្ទី ។

ដានី ៖ កាលហ្នឹងមានអ្នកចាស់ មានអ្នកថ្មី?

គា ៖ ចាំ! លាយៗគ្នា មានអ្នកថ្មីដែលនៅជុំកងជិតខ្ញុំនោះ នៅភ្នំពេញស៊ើបប្រវត្តិថាម៉ែឪគ្មាស័ក្តិមួយស័ក្តិពីរយកទៅវៃចោល គ្រាន់តែស៊ើបចាប់ផ្តើមយកទៅវៃចោល មិនដឹងយកទៅវៃណាៗទេ អ្នកមូលដ្ឋាននេះក៏ដោយឲ្យតែធ្វើប្រធានតែ៣ថ្ងៃក៏វៃចោលដែរ ។

ដានី ៖ ចុះមីងធ្លាប់ឃើញគេចាប់?

គា ៖ ឃើញៗទាល់តែតក់ស្លុតមិនហានដើរទៅណាទេ ។

ដានី ៖ មីងឃើញគេចាប់ហ្នឹង ចាប់ពេលណា ចាប់ពេលដែលលើកទំនប់ហ្នឹង?

គា ៖ ទេ! ចាប់នៅត្រពាំងថ្ម ហើយអ្នកនៅក្នុងកងខ្ញុំទៀត ហើយព្រឹកឡើងបាត់ រាប់មនុស្សទៅបាត់ ហើយមិនហានសួរទេ តែបាត់ហើយគឺយកទៅវៃចោល តែខ្ញុំនៅម្តុំគរនេះដេកជុំគ្នាទៀតកាលហ្នឹង កន្លែងគេឲ្យធ្វើ ដេកជុំគ្នាយប់ឡើង អាហ្នឹងម៉ែឪវាធ្វើការខាង

កាបុរ៉ាល់ហោះយ៉ាងម៉េចទេ ដេកនៅជាមួយគ្នាហ្នឹង យប់ឡើងផាកទៅ ចាប់យកទៅដាក់ឡានទៅទល់រហូតដល់សព្វថៃនេះ ដល់សួរទៅគេថាយកទៅវៃចោលសួរអ្នក ផ្សេងៗ ។

ដានី : កាលជំនាន់ហ្នឹង ជំនាន់នីរតីម៉ោគ្រប់គ្រងហើយឬក៏?

គា : ជំនាន់និរតីហ្នឹងអានាង ។

ដានី : ជំនាន់និរតីហ្នឹង?

គា : ចា៎!

ដានី : ជំនាន់ហ្នឹងយាយថែម គាត់?

គា : យាយថែម នៅតែយាយថែម ហ្នឹង ។

ដានី : កាលហ្នឹងមីងស្គាល់ឈ្មោះគាត់ កាលមីងទៅលើកទំនប់?

គា : ចា៎!

ដានី : ចុះពេលដែលមីងលើកទំនប់ហ្នឹង ពេលដែលអ្នកក្រុមអីជាមួយមីងទៅលើកហ្នឹងមានគេគេអីទេ?

គា : មាន កាលហ្នឹងមានគេចាប់ ។

ដានី : គេចាប់យកទៅណាទៅ?

គា : មិនដឹងគេចាប់យកណា យកទៅបាត់ទៅបាត់ទៅ ។

ដានី : យកទៅបាត់ នៅកន្លែងទំនប់ត្រពាំងថ្មហ្នឹង មានកន្លែងសម្លាប់មានអី?

គា : អ៊ូ!ច្រើនណាស់នាង ច្រើនណាស់មិនតិចទេ ម៉្លុំនេះដូចថាពួកស័ក្តិមួយ ស័ក្តិពីរ ពួកនិស្សិតពួកអីហ្នឹងហៅគ្នា កំពុងវែកហ្នឹងហៅគ្នាយកទៅវៃចោលភ្លាមៗ អត់មានថាចាំនេះទេ ។

ដានី : អត់ដឹងថាគេយកទៅវៃចោលកន្លែងណាទេ?

គា : អត់ទេ!ខ្ញុំអត់មានដឹងទេ ។

ដានី : ចុះអ្នកចាប់យកទៅវៃចោលហ្នឹងពីណាគេ?

គា : ពួកនិរតីហ្នឹងឯង ។

ដានី : មានស្គាល់ឈ្មោះគាត់ទេ?

គា : ទេ!មិនដែលស្គាល់ទេ គ្មានអ្នកណាហានទៅសួរគេ មានដូចយើងសព្វថ្ងៃណាទៅសួរណាឈ្មោះអីៗ ហានណាមិនហានទេ ខ្លាចណាស់ ។

ដានី : ចុះយាយថែម គាត់មានដែលដើរមើល?

គា ៖ អត់ទេ!ទល់តែពេលគេម៉ោប្រជុំ គេម៉ោប្រជុំបណ្ដោយ ដូចថាថ្ងៃនេះអីគេត្រូវប្រជុំ យើងនេះត្រូវអត់ធ្វើការទេ គេឲ្យឈប់សម្រាកមួយថ្ងៃ គេថាថ្ងៃនេះគេប្រជុំបើកមហាសន្និបាត គេហៅមហាសន្និបាតកាលជំនាន់នោះ ហើយយើងទៅៗ ។

ដានី ៖ អញ្ចឹងពេលប្រជុំៗ នៅកន្លែងណាទៅ?

គា ៖ ប្រជុំនៅកន្លែងត្រពាំងថ្មហ្នឹង កន្លែងលើកទំនប់ហ្នឹងឯង កន្លែងកូនខ្វែង ។

ដានី ៖ កន្លែងកូនខ្វែង កន្លែងលើកទំនប់ហ្នឹងដែរ?

គា ៖ ចា៎!កន្លែងត្រង់ហ្នឹងឯង ។

ដានី ៖ ពេលប្រជុំគេនិយាយថាម៉េចខ្លះ?

គា ៖ គេឲ្យយើងខំបង្កបង្កើនផល ខំរើសម្ញាប់ កំចាត់ពួកនាយទុន ពុករលួយគេចេះតែនិយាយទៅណា ។

ដានី ៖ ពីណាអ្នកនិយាយហ្នឹង?

គា ៖ យាយថែម ហ្នឹងឯង ។

ដានី ៖ អញ្ចឹងគាត់ម៉ោប្រជុំអញ្ចឹង ម៉េចអត់ដែលឃើញមុខគាត់ទេ?

គា ៖ ចុះបើនៅឆ្ងាយអញ្ចឹង ។

ដានី ៖ ចុះមើលឃើញគាត់ប្អអត់?

គា ៖ ឃើញគាត់ ស្គមខ្មៅ ។

ដានី ៖ ស្គម ខ្មៅ?

គា ៖ ចា៎!

ដានី ៖ ហើយគាត់ម៉េចទៅ មនុស្សគាត់?

គា ៖ មនុស្សគាត់បើនិយាយនៅតាមអង្គប្រជុំដូចស្រួលដែរ តែដល់ពេលគាត់ត្រូវសម្លាប់ ដូចកាចសាហាវណាស់ ។

ដានី ៖ ដល់ពេលប្រើសម្លាប់កាចសាហាវ?

គា ៖ ចា៎!យើងខុសអី គេមានហៅយើងយកទៅសួរណា យកយើងទៅវ៉ៃចោលភ្លាម ។

ដានី ៖ ប៉ុន្មានចំងាយណាពីមីងអង្គុយប្រជុំ?

គា ៖ ប្រជុំណា បើខ្ញុំអង្គុយនេះហ្នឹង ព្រោះគ្នាវាច្រើន មនុស្សច្រើនណាស់រាប់ពាន់ ។

ដានី ៖ មនុស្សរាប់ពាន់?

គា ៖ ចា៎!

ដានី ៖ អញ្ចឹងពេលមីងអង្គុយហ្នឹង មានចំងាយប្រហែលប៉ុន្មានពីយាយថែម ប្រហែលប៉ុន្មានម៉ែត្រទៅ?

គា ៖ ប្រហែល១០០ម៉ែត្រ ។

ដានី ៖ អញ្ចឹងពេលប្រជុំម្ដងៗគេហៅអ្នកលើកម៉ោទាំងអស់?

គា ៖ ទាំងអស់គ្នា ។

ដានី ៖ ចុះប្រជុំជាមួយយាយថែម មានពីណាខ្លះទៀត?

គា ៖ អ្ហូ!ច្រើនណាស់ យើងមិនស្គាល់គេទេ ។

ដានី ៖ ប៉ុន្ដែយាយថែម គាត់ធំជាងគេ?

គា ៖ ចា៎!ធំជាងគេ ដល់បន្ទាប់ពីយាយថែមម៉ោ គាត់មានលំដាប់ដូចយើងសព្វថ្ងៃអញ្ចឹងណា៎ គាត់មានប្រធានអនុប្រធាន ។

ដានី ៖ មីងដែលស្គាល់ទេ?

គា ៖ មិនដែលស្គាល់ទេខ្ញុំ ។

ដានី ៖ សាល់តែយាយថែម?

គា ៖ ចា៎!

ដានី ៖ យាយថែម រាងខ្មៅស្គម?

គា ៖ ចា៎!

ដានី ៖ ពេលគាត់ប្រជុំម្ដងៗ គាត់ថាឲ្យយើងខំបង្កបង្កើនផល កំចាត់មេទុនអញ្ចឹង?

គា ៖ ចា៎!

ដានី ៖ ពេលដែលគាត់ម៉ោប្រជុំហ្នឹង រយៈពេលប៉ុន្មានបានម៉ោប្រជុំម្ដង?

គា ៖ ១ខែៗម៉ោម្ដង ដែលខ្ញុំទៅលើកនេះ ទៅលើកចំនួន៦ខែនេះ គាត់ទៅប្រជុំ២ដង ។

ដានី ៖ គាត់ប្រជុំ២ដង?

គា ៖ ចា៎!

ដានី ៖ មីងចាំថា ក្រៅពីគាត់និយាយបង្កបង្កើនផល មីងមានចាំថាគាត់មាននិយាយអីទៀត ទេ?

គា ៖ ដូចជាយូរទៅចាំវាមិនបានទេ ។

ដានី ៖ ចុះកន្លែងដេកពួនអីយ៉ាងម៉េចទៅ?

គា ៖ ដេកនៅដីហ្នឹង ។

ដានី ៖ ដេកនៅដី អត់មានក្រាលអីទេ?

គា ៖ ក្រាលកន្ទេល យើងមានកន្ទេលយើងយកទៅហ្នឹង អ្នកខ្លះមិនប៉ុនមានក្រណាត់កៅស៊ូ យើងក្រាលដេកទៅ ។

ដានី ៖ អញ្ចឹងម្នាក់មាំម៉ែត្រគីបទៅមួយម៉ែត្រកន្លះ?

គា ៖ ចាំ!

ដានី ៖ ប្រុសៗក៏ប៉ុនហ្នឹងដែរ?

គា ៖ ចាំ!

ដានី ៖ ចុះបើកម្លាំងប្រុស កម្លាំងស្រីខុសគ្នា?

គា ៖ ចុះគេថាអញ្ចឹង កម្លាំងស្រី ប្រុសយើងមានសិទ្ធស្មើគ្នាគេឲ្យទៅធ្វើ ។

ដានី ៖ សិទ្ធស្មើគ្នាមែន ប៉ុន្តែធម្មជាតិបង្កើតម៉ោមនុស្សស្រីវាខ្សោយជាងមនុស្សប្រុស?

គា ៖ គេអត់និយាយថាអញ្ចឹងទេ គេនិយាយថាឲ្យតែមួយថ្ងៃឲ្យហើយក្នុងមាំម៉ែត្រគីប ។

ដានី ៖ បាទ!អញ្ចឹងមនុស្សធ្វើឆាប់ហើយជាង?

គា ៖ មនុស្សប្រុសណាគ្នាយ៉ាប់ក៏យ៉ាប់ដែលនាង យ៉ាប់ជាងមនុស្សស្រីទៅទៀត មិនឲ្យគ្នាស៊ីបបូរណ៍ហើយលើក អាទឹកក៏គ្មានផឹក ទឹកគេចែកឲ្យទឹកទៀត ។

ដានី ៖ ទឹកចែកឲ្យហូបទៀត អត់មានបបូរណ៍ទេ?

គា ៖ អត់ទេ!បើយើងចង់ទៅផ្លូតទាល់តែម៉ោង១២ ពេលយើងរមាស់ខ្លាំងអីខ្លាំងទៅ យើងទៅរែកឆ្ងាយណាស់ ហួសពីហ្នឹងទៅទៀត បានយកមកទឹកក៏ចែកគ្នាហូបទៅ រែកបំពង់រែកអីទៅ ដល់រានយ៉ាំងទៅ ក្នុងមួយក្រុមចាប់មនុស្សម្នាក់ឲ្យទៅរែកទឹកយកមកឲ្យផឹក បើអ្នកណាបានទៅរែកទៅ អាហ្នឹងបានផ្លូតទៅណា៎ ដែលពួកយើងអ្នកលើកម៉ែត្រគីប នេះយប់ឡើងដេកទាំងអស់ ដល់ចៃចេញតាមសាច់ ។

ដានី ៖ អញ្ចឹងអ្នកដែលម៉ោប្រជុំ គេគ្រប់គ្នាស្គាល់យាយ ចែម ទាំងអស់ដឹងថាយាយចែមគាត់ធ្វើប្រធាន?

គា ៖ ចាំ!

ដានី ៖ ផ្សេងៗទៀតអត់ស្គាល់ទេ?

គា ៖ អត់ស្គាល់ទេ ។

ដានី ៖ ចុះកន្លែងអ្នកដែលម៉ោចាប់ហៅ ដូចថាមីងកំពុងតែធ្វើការៗអញ្ចឹង គេម៉ោហៅគេចាប់យកទៅអីអត់ដឹងថាពីណាអ្នកណាទេ?

គា ៖ អត់ដឹងទេនាង មិនហានទេ បើថាគេចាប់យកទៅ យើងកាប់ដីវែកៗអញ្ចឹងទៅ ចាប់ណាក៏ចាប់ទៅ ។

ដានី ៖ បាទ!ចាប់ហ្នឹងគេចាប់យកទៅហើយ មានដែលចាប់ហើយគេប្រឡែងមកវិញឬអត់?

គា ៖ ទេ តែចាប់ហើយក៏ហើយ គ្មានចាប់ហើយប្រឡែងដូចយើងសម័យនេះទេ ចាប់បានតែចាប់អានាងឯងទៅអានាងបាត់ខ្លួន ចាប់ខ្ញុំទៅខ្ញុំបាត់ខ្លួន អត់មានចាប់ហើយប្រឡែងមកវិញទេ ។

ដានី ៖ ចុះកន្លែងដាក់គុក កន្លែងគេសម្លាប់អី នៅកន្លែងត្រពាំងថ្មហ្នឹងមានកន្លែងដាក់ទេ?

គា ៖ គេអត់មានកន្លែងទេ មិនដឹងយកទៅវៃចោលណាទេ ។

ដានី ៖ អត់ដឹងទេ?

គា ៖ អត់ដឹងទេ ។

ដានី ៖ បើតាមមីងប៉ាន់ស្មានទៅច្រើនទេ?

គា ៖ ច្រើនណាស់នាង ច្រើនណាស់ ងាប់ក៏ងាប់ អាដូចថាគ្មានឈឺទៅគ្មានថ្នាំព្យាបាលទៅក៏ ងាប់ ។

ដានី ៖ អត់មានពេទ្យទេកាលលើកទំនប់ហ្នឹង?

គា ៖ ពេទ្យណា បើថ្នាំមិនដឹងជាថ្នាំអីទេ សូន្យៗខ្មៅចេះតែឲ្យគ្នាលេបឲ្យនេះទៅ មិនដូចយើងសព្វថ្ងៃមានសារ៉ូមមានថ្នាំគ្រប់មុខប្រភេទដូចថា ជំងឺនេះត្រូវលេបថ្នាំប្រភេទនេះអញ្ចឹង អត់តែថ្នាំសូន្យៗប៉ុនៗនេះទេ ឲ្យគ្នាលេបទៅ គ្មានលេបឲ្យនឹងបាត់ ឲ្យគ្នាហូបមិនបានគ្រប់គ្រាន់ទៅ ប្រើយើងធ្វើការនឿយទៅ ។

ដានី ៖ ចុះមន្ទីរពេទ្យអី អ្នកឈឺដើរមិនរួចត្រូវដេកពេទ្យអី ទៅដេកណា?

គា ៖ ដេកនៅពេទ្យស្វាយហ្នឹង គេហៅចល័តតំបន់គេនោះ ឲ្យតែឈឺឡានគេដឹកម៉ោស្វាយ ហ្នឹង ។

ដានី ៖ ចល័តតំបន់?

គា ៖ ចាំ!

ដានី ៖ ចល័តតំបន់នៅណាទៅ?

គា ៖ នៅហ្នឹងស្វាយហ្នឹង គេហៅស្វាយៗស្វាយគេទៅ ។

ដានី ៖ ចុះកងចល័តតំបន់ពីណាខ្លះ មីងអត់ស្គាល់ទេ?

គា ៖ អត់ស្គាល់ទេ គេថាចល័តតំបន់ៗ កាលនោះចល័តគេធំ ចល័តពិសេសគេ ពុតែគេថាដូចពួកខ្ញុំចល័តធំអញ្ចេះ ពេទ្យព្យាបាលចេះហើយ មានកន្លែងណា ព្រឹកឡើងគេចែកថ្នាំដូចថាមានអ្នកឈឺ ។

ដានី :	អកណាគេប្រធានកងចល័តតំបន់?

គា :	អត់ស្គាល់ទេនាង ខ្ញុំមិនដែលស្គាល់ទេ ។

ដានី :	ចុះឈ្មោះ បឿន ឈ្មោះតាក្រុកអីគាត់នៅរស់ណា?

គា :	មិនដឹងជារស់ មិនដឹងជាស្លាប់ទេ ។

ដានី :	អត់ដែលជួបគ្នាទេ?

គា :	ចា៎!អត់ដែលជួបផង ។

ដានី :	អញ្ចឹងកាលហ្នឹងមីងជួបយាយថែម គាត់ម៉ោប្រជុំតែ២ដងទេ កាលមីងធ្វើនៅនោះ?

គា :	ចា៎!២ដងទេ ។

ដានី :	បានជួបឃើញគាត់ពីចំងាយ?

គា :	ចា៎!ឃើញពីចំងាយ ខ្ញុំដាំបាយហ្នឹង អ្នកដាំបាយឲ្យគេ ដល់ពេលគេប្រជុំអញ្ចឹងយើងដាំបាយឲ្យគេ ដល់ប្រជុំរួចនាំគ្នាហូបទៅ ខ្ញុំគេឲ្យឈប់មួយថ្ងៃហ្នឹង ព្រឹកឡើងក៏ចាប់ផ្តើមធ្វើការទៀត ។

ដានី :	ពេលប្រជុំគេឲ្យឈប់មួយថ្ងៃ?

គា :	ចា៎!គេឲ្យឈប់មួយថ្ងៃ ។

ដានី :	ពេលប្រជុំៗយូរទេ?

គា :	យូរ! យូរណាស់ប្រហែល២ម៉ោង ។

ដានី :	២ម៉ោង?

គា :	ចា៎!

ដានី :	យាយថែម គាត់និយាយម្នាក់ឯងឬមានអ្នកផ្សេងទៀត?

គា :	អេ៎!មានអ្នកផ្សេងទៀត គាត់និយាយបានប្រហែល២-៣មាត់ទៅក៏មានអ្នកបន្ទាប់ពីគាត់ហ្នឹង ឡើងធ្វើការទៅណា៎ បន្តបន្ទាប់គ្នាទៅ ។

ដានី :	ហើយចុះក្រៅពីជួបគាត់ពី២ដងមានជួបគាត់ទៀតទេ?

គា :	ទេ! មិនដែលជួបទេៗ ។

ដានី :	ចុះកាលហ្នឹងគេនិយាយថាលើកទំនប់ត្រពាំងថ្មនៅតំបន់៥?

គា :	ចា៎!នៅតំបន់៥ ។

ដានី :	ពីណាអ្នកនិយាយថាអញ្ចឹង?

គា ៖ ចុះគេប្រជុំថានៅតំបន់៥យើងនេះ មុននឹងគេឲ្យទៅលើកគេប្រជុំៗថា តំបន់៥នេះឲ្យទៅលើកអាងត្រពាំងថ្មយើងសព្វថ្ងៃនេះ ។

ដានី ៖ អ្នកណាគេអ្នកប្រជុំនោះអញ្ចឹង?

គា ៖ ប្រធានភូមិយើង ។

ដានី ៖ ពីណាគេ ឈ្មោះអីគេ?

គា ៖ ប្រធានភូមិហ្នឹងគេយកទៅវ៉ៃចោលបាត់បាត់ ឈ្មោះតាអីក្មេច អូ!ឈ្មោះតាមឿន គេវ៉ៃចោល ។

ដានី ៖ តាមឿន គេវ៉ៃចោល?

គា ៖ ចា៎!គេវ៉ៃចោលអស់ហើយ ។

ដានី ៖ គេប្រាប់ឲ្យម៉ោតំបន់៥ហ្នឹង?

គា ៖ ចា៎!

ដានី ៖ កាលហ្នឹងមីងអត់ស្គាល់តំបន់៥ទេ?

គា ៖ មិនដែលស្គាល់ទេនាងអើយ! អ្នកណាទៅគិតគូរអារឿងហ្នឹង ធ្វើម៉េចឲ្យតែរែករួច ។

ដានី ៖ ចុះមីងដឹងយាយថែម គាត់មានតួនាទីអី?

គា ៖ មិនដឹងជាមានតួនាទីអីទេ គេថាយាយថែមៗទៅ ខ្ញុំឮតែឈ្មោះគាត់ហ្នឹង ។

ដានី ៖ បាទ!ចុះមីងម៉េចបានទៅលើកបានតែ៦ខែ បានគេផ្លាស់មីងទៅកន្លែងដើមគរ៣ដើម?

គា ៖ អាហ្នឹងរួច រួចអស់ហើយនាង ។

ដានី ៖ រួចអស់ហើយ?

គា ៖ ចា៎!

ដានី ៖ មីងចាំថារួចអស់ឆ្នាំណា?

គា ៖ មិនដឹងជាឆ្នាំណាមិនបានជាគិត ។

ដានី ៖ ជិតបែកប្អូនៅ ជិតយួនចូលប្អូនៅ?

គា ៖ នៅអត់ទាន់បែកទេនាង នៅដែនការយូរគ្រាន់បើ ដែលយួនចូលនេះខ្ញុំបានគ្រួសារ គេបើកវគ្គ គេហៅបើកវគ្គ ខ្ញុំបានគ្រួសារគេឲ្យទៅច្រូតនៅវាលម្តុកព្រែងយើងនេះណា៎ ។

ដានី ៖ អញ្ចឹងដល់ពេលយើងលើកទំនប់ត្រពាំងថ្មហើយទៅ ទំនប់ហ្នឹងគេយកទៅធ្វើអីទៅ?

គា ៖ គេគ្មានយកធ្វើអីទេ ឃើញនៅមកទល់សព្វថ្ងៃនេះ គេធ្វើអាង ។

ដានី ៖ កាលហ្នឹងគេលើកទំនប់ហ្នឹងដើម្បីយកទៅធ្វើអី?

គា ៖ ធ្វើអាង ។

ដានី ៖ អាងស្តុបទឹក?

គា ៖ ចា៎! ទុកបង្ហូរគេធ្វើស្រែប្រាំងស្រែអីហ្នឹង ដែលគេធ្វើការណា៎ ។

ដានី ៖ ហើយអាងគេនៅដដែល?

គា ៖ ចា៎! ហើយគេមិនទាន់បានធ្វើរដ្ឋប្រហារទៅ ។

ដានី ៖ ចុះបន្ទាប់ពីហ្នឹងហើយ ម៉ោកន្លែងគរពាដើមធ្វើអីវិញទៅ?

គា ៖ ធ្វើស្រែៗ ស្ទូង ដកស្ទូងទៅ ដកស្មៅទៅ ខែច្រូតក៏ច្រូតទៅ ។

ដានី ៖ គរពាដើមហ្នឹងនៅស្រុក??

គា ៖ ចា៎!

ដានី ៖ កន្លែងហ្នឹងគេហៅពាគរពាដើមហ្នឹងភូមិឬក៏អី?

គា ៖ អត់មានភូមិទេ នៅកណ្តាលវាល ។

ដានី ៖ មានដើមគរពាដើម?

គា ៖ ចា៎!មានគរពាដើម ដាំតាមថ្នល់អញ្ចឹងទៅគេហៅគរពាដើម ។

ដានី ៖ មីងធ្វើហ្នឹងបានរយៈពេលប៉ុន្មានបានម៉ោស្រុក ?

គា ៖ ខ្ញុំធ្វើបានប្រហែល២ខែ ។

ដានី ៖ ២ខែម៉ោស្រុក?

គា ៖ ចា៎!ម៉ោស្រុក គេស្នើគ្រួសារខ្ញុំទៅបើកវគ្គទៅ គេឲ្យនៅជុំចាស់ៗ ។

ដានី ៖ មីងម៉ោដល់ស្រុកវិញបានគ្រួសារស្នើ?

គា ៖ ចា៎!

ដានី ៖ មីងរៀបការបានប៉ុន្មានខែបានបែកអាពត?

គា ៖ ប្រហែលខែ៦ៗអាពតចេញ ។

ដានី ៖ ៦ខែបានប៉ុល ពតចេញ?

គា ៖ ចា៎!

ដានី ៖ ចុះមីងកាលមីងនៅជាំបាយនៅទំនប់ត្រពាំងថ្មហ្នឹង មីងដាំគ្នាប៉ុន្មាននាក់ទៅជាំបាយ?

គា ៖ គ្នា៥នាក់ ។

ដានី ៖ គ្នា៥មាក់?

គា ៖ ចា៎!

ដានី :　គ្នា៥នាក់ដាំបាយឲ្យប៉ុន្មានក្រុម?

គា :　៥ក្រុម ។

ដានី :　គ្នា៥នាក់ដាំបាយឲ្យ៥ក្រុម?

គា :　ចា៎!

ដានី :　៥នាក់ហ្នឹងដាំបាយ ចែកការងារម្នាក់ៗឲ្យធ្វើការងារអីខ្លះ?

គា :　អ្នកណាដាំបាយក៏ដាំបាយទៅ អ្នកណាស្ងក៏ស្ងទៅណា អាអ្នករកអុសរកអុសទៅ ។

ដានី :　ក្នុង៥នាក់ហ្នឹង?

គា :　ចា៎!

ដានី :　ស្រីៗទាំងអស់?

គា :　ចា៎!

ដានី :　អ្នករកអុសៗ អ្នកដាំបាយៗ អ្នកស្ងៗ?

គា :　ចា៎!

ដានី :　អ្នករកអុសប៉ុន្មាននាក់?

គា :　អករកអុស២នាក់ ។

ដានី :　អ្នកដាំបាយ?

គា :　អ្នកដាំបាយ៣នាក់ ។

ដានី :　ដាំបាយ ហើយស្ង៣នាក់?

គា :　ចា៎!

ដានី :　អត់ដែលមានបញ្ហាអីទេអ្នកដាំបាយ?

គា :　មិនដែលចេះឈ្លោះគ្នាទេ បើឈ្លោះគ្នាគេហៅយកទៅក៏សាងយកទៅវ៉ៃចោល ។

ដានី :　ខ្លាចហ្នងកាលហ្នឹង?

គា :　ហ៊ឺ!ខ្លាចណាស់ ឃើញគួរតែតក់ស្លុតណាស់សម័យកាលហ្នឹង ។

ដានី :　ពួកកម្មាភិបាលម៉ោពីខាងនិរតីយ៉ាងម៉េចដែរ អត្តចរិកគេ?

គា :　ហ៊ឺ!អត្តចរិកគេកាចណាស់ គេមិននិយាយទេ គេតាមដានយើង គេមើលគោលជំហរយើង ដូចមើលយើងធ្វើអី ម៉ែឪយើងធ្វើអីគេតាមដានយើង ម៉ែឪយើងធ្វើស្រែទៅគេទុកយើងទៅ បើថាម៉ែឪយើងមានធ្វើការបន្តិចបន្តួច ដូចពីដើមឡើយថាភូមិចំគុប

អញ្ចឹងទៅមានប្រវត្តិគេយកទៅវៃចោលទៅ គេស្រាវជ្រាវប្រវត្តិយើងថាមានធ្វើអីឪយើងមានធ្វើអីធ្វើប៉ូលីស ធ្វើគ្រូបង្រៀនអីគេវៃចោល ។

ដានី : ចុះមីងគ្រួសារមីងមានស្លាប់អត់សម័យខ្មែរក្រហម?

គា : មាន មានបងខ្ញុំបងួស់ប្តីធ្វើទាហាន គេយកទៅវៃចោល ។

ដានី : គេយកទៅវៃចោលនៅណា?

គា : មិនដឹងជាវៃចោលនៅណា គេថាវៃចោលនៅផ្ទះហ្នឹង គេហ្នឹងចាប់ទៅដល់អ៊ិនគួន គេថាអ្នកធ្វើទាហាន៣ថ្ងៃគេចាប់យកទៅវៃចោល ដល់នេះគាត់រត់ៗទៅមិនដឹងឈប់ឯណាឯណីទេ ដល់នេះទៅប្រពន្ធគេចាំជម្លៀស ប្រធាបភូមិដូចភូមិយើងចេះឯង គេស្រណោះប្រជាជនស្មើ ឲ្យយកទៅដាក់នៅក្នុងត្រយ៉ូង ដូចនេះនាំគ្នាធានាថាបើសិនជាប្តីមករកឃើញគេចាប់ មិនហ៊ានចាប់ទេគេថាយើងហ៊ានចាប់តែប្តីមួយ គេទុកឲ្យទៅ ពួកអ្នករត់ៗទៅងាប់អស់ ។

ដានី : បាទ!អញ្ចឹងគ្រួសាររបស់បងអ្នកមីងស្លាប់តែប្តីទេ?

គា : ចា៎!

ដានី : ប្រពន្ធកូនអត់អីទេ?

គា : អត់ ។

ដានី : ចុះមីងកាលគេស្មើមីងរៀបការហ្នឹង រៀបការប៉ុន្មានគូរ?

គា : ១២០គូរ ។

ដានី : កាលហ្នឹងប្តីរបស់មីងគាត់ធ្វើអី?

គា : ធ្វើស្រែ គាត់ខាងស្រែ គាត់ភ្ជួរធ្វើស្រែ ។

ដានី : កាលហ្នឹងខ្មែរក្រហមគេស្មើរៀបចំឲ្យគាត់ឬក៏គាត់ស្មើខ្លួនគាត់?

គា : ម៉ែឪស្មើ ។

ដានី : ម៉ែឪស្មើបានដែរ?

គា : ចា៎!ស្មើបាន ។

ដានី : ដល់ពេលឃួនចូលហ្នឹងមីងអត់រត់ទៅណាទេ?

គា : រត់ទៅនៅខាងនោះកូនថ្មីទៅទៀតណាខាង ។

ដានី : ខាងណា?

គា ៖ នៅនេះម៉ាជួរយើងកូនថ្មីយើង ម៉ាជួរជួវទៅកូនថ្មី ម៉ាជួរស្រែរនាមតាមដងព្រៃនេះ នេះនៅក្នុងវាលនេះ យប់ឡើងវាម៉ោ ។

ដានី ៖ ពីណាម៉ោ?

គា ៖ ពួកអាពតហ្នឹង ។

ដានី ៖ ចុះមីងម៉េចបានរត់ទៅហ្នឹង?

គា ៖ ចុះមិនហ៊ានៅក្នុងភូមិនោះខ្លាចគេចាប់យកទៅស្មើ គៀរយកទៅអស់ហើយ មានអ្នកគៀរយកទៅ អ្នកភូមិខ្ញុំនៅសល់២-៣នាក់ហ្នឹង ។

ដានី ៖ អាពតគៀរយកទៅ?

គា ៖ ចា៎!

ដានី ៖ ចុះពេលហ្នឹង ពេលយួនចូលម៉ោចុះយើងម៉េចមិនទៅជាមួយយួន?

គា ៖ ទៅជាមួយយួនម៉េចបើយួននៅឆ្ងាយ យើងនៅជប់នេះ យើងនៅនេះការពារទៅហើយនាំគ្នារត់គេច ។

ដានី ៖ រត់គេចខ្លាចអាពតគេសម្លាប់?

គា ៖ ចា៎!

ដានី ៖ រយៈពេលប៉ុន្មានទៅបានម៉ោវិញ?

គា ៖ ប្រហែលកន្លះខែ ឬមួយខែអីមិនដឹងកាលហ្នឹង ដល់យួននៅក្នុងភូមិ បាននាំគ្នាម៉ោនៅតាមភូមិវិញ ។

ដានី ៖ មីងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំមីងទៀតហើយ អញ្ចឹងមីងមានអីចង់បន្ថែមទៀត ទេ?

គា ៖ ខ្ញុំអត់មានអីបន្ថែមទេ ។

ដានី ៖ បាទ!អញ្ចឹងខ្ញុំអរគុណមីងច្រើន ។

គា ៖ ចា៎!

«ចប់»